ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥០៤ ប្រក. កសក

# ប្រកាស
# ស្តីពី
# ការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ ខេត្តព្រះសីហនុ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និង មាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញប្រកាសលេខ៥៧១ ប្រក.កសក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីវិធានការការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្ម រាជធានី ខេត្ត និងដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតក្រោមមន្ទីរកសិកម្ម រាជធានី ខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

### ប្រការ១.-

ត្រូវបានបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ដែលមានផ្ទៃក្រឡាសរុប ១០ ៩២៣ (ដប់ពាន់ប្រាំបួនរយម្ភៃបី) ហិកតា ស្ថិតក្នុងភូមិសាស្ត្រនៃឃុំទឹកថ្លា ទឹកល្អក់ សាមគ្គី សំរ៉ុង អណ្តូងថ្ម និងឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានផែនទី និងនិយាមការ (Datum WGS 84) ភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

### ប្រការ២.-

ការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់នេះ មានគោលបំណងដើម្បី៖

- គ្រប់គ្រងធនធានជលផល និងជីវចម្រុះសមុទ្រនៅតំបន់ព្រែកកំពង់ស្មាច់ប្រកបដោយនិរន្តរភាព
- ធានាបានប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរឱ្យប្រសើរឡើង
- ធានាបានការនេសាទជាលក្ខណៈគ្រួសារ ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- លើកស្ទួយវិស័យអេកូទេសចរណ៍
- ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

### ប្រការ៣.-

តំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ខេត្តព្រះសីហនុ ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលជលផល និងរដ្ឋបាលខេត្តព្រះសីហនុ ដែលមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- រៀបចំក្រុមការងារគ្រប់គ្រង ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ
- កំណត់ និងបែងចែកកន្លែងគ្រប់គ្រងនានាក្នុងតំបន់គ្រប់គ្រងជលផល ដោយមានការពិគ្រោះយោបល់ជាមួយសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន និងសហគមន៍នេសាទពាក់ព័ន្ធ
- រៀបចំ និងអនុវត្តផែនការគ្រប់គ្រង
- បោះបង្គោល ដាក់ពោង និងស្លាកសញ្ញា

- បង្កើតក្រុមល្បាត ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល និងសកម្មភាពផ្សេងៗ ដែលប៉ះពាល់ដល់ធនធានជលផល
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងផ្គត់ផ្គង់សម្ភារ សម្រាប់គាំទ្រដល់សកម្មភាពល្បាត ត្រួតពិនិត្យបទល្មើសជលផល ការសិក្សាស្រាវជ្រាវ និងអេកូទេសចរណ៍
- កែលម្អទីជម្រក តាមរយៈការដាំដើមកោងកាង និងបង្កើតជម្រកសិប្បនិម្មិត
- សិក្សាស្រាវជ្រាវលក្ខណៈជីវសាស្ត្រនៃធនធានជលផលសំខាន់ៗ និងផលចាប់
- អប់រំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងសារៈសំខាន់នៃធនធានជលផលដល់អ្នកពាក់ព័ន្ធ ដើម្បីចូលរួមថែរក្សា ការពារ និងអភិរក្ស
- បង្កើនមុខរបរបន្ថែមដល់សហគមន៍មូលដ្ឋាន ដើម្បីលើកកម្ពស់ជីវភាពរស់នៅ
- ចូលរួមដោះស្រាយទំនាស់ ដែលពាក់ព័ន្ធនឹងវិស័យជលផល
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន
- ស្វែងរកថវិកាសម្រាប់គាំទ្រសកម្មភាពគ្រប់គ្រង។

**ប្រការ៤.-**

កន្លែងអភិរក្សជលផល កន្លែងការពារជលផល ដែនជម្រកសុវត្ថិភាពជលផល កន្លែងអភិវឌ្ឍន៍វារីវប្បកម្ម និងកន្លែងអេកូទេសចរណ៍ជលផល ក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ខេត្តព្រះសីហនុ ដែលនឹងត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៥.-**

ហាមឃាត់ការធ្វើនេសាទដោយប្រើឧបករណ៍អួនអូស ឈឺបយន្ត ឧបករណ៍អូសគ្រែងឈាមដោយម៉ាស៊ីន និងឧបករណ៍នេសាទខុសច្បាប់ព្រមទាំងសកម្មភាពផ្សេងៗទៀតដែលបង្កឱ្យប៉ះពាល់ដល់ធនធានជលផល និងជីវចម្រុះក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ខេត្តព្រះសីហនុ។

**ប្រការ៦.-**

ប្រភពថវិកាសម្រាប់គ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ខេត្តព្រះសីហនុ មានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន
- ជំនួយសប្បុរសជន
- ចំណូលផ្សេងៗ។

**ប្រការ៧.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៤កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០២២

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះសីហនុ
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ៥០៤ កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ខេត្តព្រះសីហនុ




# ផែនទី បង្ហាញព្រំប្រទល់តំបន់គ្រប់គ្រងជលផលសមុទ្រ ព្រែកកំពង់ស្មាច់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

**Boundary Map of Marine Fishery Management of Kampong Smach, Prey Nob District, Preah Sihanouk Province**

............ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២

**គណៈកម្មការ/សហគមន៍**

ហួត_ម៉ូរ៉ា

លេខ: ........ បានឃើញ និងពិនិត្យត្រឹមត្រូវ ........ថ្ងៃទី.... ខែ.... ឆ្នាំ២០២២ **មេឃុំទួលទទឹង** ឯម សុគា

លេខ: ........ បានឃើញ និងពិនិត្យត្រឹមត្រូវ ........ថ្ងៃទី.... ខែ.... ឆ្នាំ២០២២ **មេឃុំអណ្តូងថ្ម**

លេខ: ........ បានឃើញ និងពិនិត្យត្រឹមត្រូវ ........ថ្ងៃទី.... ខែ.... ឆ្នាំ២០២២ **មេឃុំសំរុង** ហ៊ុ អាន

លេខ: ........ បានឃើញ និងពិនិត្យត្រឹមត្រូវ ........ថ្ងៃទី.... ខែ.... ឆ្នាំ២០២២ **មេឃុំទឹកល្អក់** ជុន ស៊ុនហេង

លេខ: ........ បានឃើញ និងពិនិត្យត្រឹមត្រូវ ........ថ្ងៃទី.... ខែ.... ឆ្នាំ២០២២ **មេឃុំសាមគ្គី** ជី សេង

លេខ: ........ បានឃើញ និងពិនិត្យត្រឹមត្រូវ ........ថ្ងៃទី.... ខែ.... ឆ្នាំ២០២២ **មេឃុំទឹកថ្លា** ជុំ ធាន

លេខ: ២២៦ / ២២ អភស

**បានឃើញ និងឯកភាព**

ថ្ងៃសុក្រ ១១កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹង ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២

**អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ**

គួច_ចំរើន

លេខ: ........ កសក.ខសន

**បានឃើញ និងពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ មេត្តាពិនិត្យ និងសម្រេច ដ៏ខ្ពង់ខ្ពស់

ថ្ងៃសុក្រ ៣ កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹង ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ២០២២

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ**

ទេព ចំរើន

លេខ: ........

**បានឃើញ និងពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ មេត្តាពិនិត្យ និងសម្រេច ដ៏ខ្ពង់ខ្ពស់

ថ្ងៃ........ ខែ........ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ត្រូវនឹង ថ្ងៃទី១៥ ខែ.... ឆ្នាំ២០២២

**អភិបាល នៃគណៈអភិបាលស្រុកព្រៃនប់**

ស_កក្កដា

លេខ: ........

**បានឃើញ និងពិនិត្យត្រឹមត្រូវ**

............ថ្ងៃទី.... ខែ.... ឆ្នាំ២០២២

**ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកព្រៃនប់**

ម៉ម សុខុម